ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**
មណ្ឌលសិក្សាបច្ចេកទេសធនាគារ
លេខ ៥១១-០១៥.១៥៧ សលា

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ ២០១៥

# សេចក្តីជូនដំណឹង
# ស្តីពីការជ្រើសរើសនិស្សិតចូលរៀន
# ថ្នាក់បរិញ្ញាបត្ររងជាន់ខ្ពស់បច្ចេកទេសធនាគារ
# ជំនាន់ទី ២៥ នៅមណ្ឌលសិក្សាបច្ចេកទេសធនាគារ

## I. លក្ខខណ្ឌចុះឈ្មោះប្រឡង

អាចចុះឈ្មោះប្រឡងបាន ចំពោះបេក្ខជនដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រដែលមានតំលៃស្មើ និងមន្ត្រីក្នុងប្រព័ន្ធធនាគារជាតិ ដែលមានបទពិសោធន៍ការងាររយៈពេលពីរឆ្នាំយ៉ាងតិច ។

## II. ចំនួនជ្រើសរើស កាលបរិច្ឆេទ វិញ្ញាសា និង រយៈពេលប្រឡង

១. ចំនួនជ្រើសរើស : សរុប **១០០ នាក់**

២. កាលបរិច្ឆេទប្រឡង : **ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៥**

៣. វិញ្ញាសា និងរយៈពេលប្រឡង

| | | |
|---|---|---|
| - ចំណេះដឹងទូទៅ | ១ ម៉ោង ៣០ នាទី | មេគុណ ២ |
| - គណិតវិទ្យា | ១ ម៉ោង ៣០ នាទី | មេគុណ ២ |
| - ភាសាអង់គ្លេស | ១ ម៉ោង ៣០ នាទី | មេគុណ ៣ |

## III. កាលបរិច្ឆេទផ្សព្វផ្សាយ និង លក់ពាក្យប្រឡង

| | |
|---|---|
| - ចាប់ផ្សព្វផ្សាយ និងលក់ពាក្យពី | **ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៥** តទៅ |
| - ចាប់ទទួលពាក្យពី | **ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១៥** |

## IV. កាលបរិច្ឆេទឈប់ទទួលពាក្យ និង បិទឈ្មោះ

| | |
|---|---|
| - ឈប់ទទួលពាក្យត្រឹម | **ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៥** |
| - បិទឈ្មោះប្រឡង | **ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៥** |



ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៩២៦ ១១៧

## V. **សំណុំលិខិតបេក្ខជនមាន**

- ពាក្យសុំចុះឈ្មោះប្រឡង............................................................ ០១ ច្បាប់
- មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រដែលមានតំលៃស្មើ ។ ចំពោះមន្ត្រីធនាគារជាតិត្រូវបញ្ជាក់ពីសាមីនាយកដ្ឋាន និងនាយកដ្ឋានបុគ្គលិក.................................. ០១ ច្បាប់
- សលាកប័ត្រឯកត្តជន.................................................................... ០១ ច្បាប់
- ប្រវត្តិរូបសង្ខេប ........................................................................ ០១ ច្បាប់
- កិច្ចសន្យា................................................................................ ០១ ច្បាប់
- រូបថតទំហំ ៤x៦ ......................................................................០២ សន្លឹក

**កំណត់សំគាល់** :

១. កម្មវិធីសិក្សាគឺប្រព្រឹត្តទៅ **រៀងរាល់ល្ងាច** ( ថ្ងៃធ្វើការ ម៉ោង ១៣:០០ ដល់ម៉ោង ១៧:៣០នាទី ) ។

២. បេក្ខជនត្រូវសរសេរបំពេញសំណុំពាក្យប្រឡង និងមកដាក់ដោយផ្ទាល់ខ្លួន ។

៣. កន្លែងលក់ និងទទួលពាក្យនៅការិយាល័យរដ្ឋបាល មណ្ឌលសិក្សាបច្ចេកទេសធនាគារ ។

៤. មិនត្រូវភូតកុហក និងសរសេរបន្លំពាក្យប្រឡងឡើយ ។ ល្អីកណាបេក្ខជនមិនគោរពតាមលក្ខខណ្ឌខាងលើនឹងត្រូវទទួលទោសតាមច្បាប់ ហើយត្រូវបានលុបឈ្មោះចេញពីបញ្ជីប្រឡង ឬលទ្ធផលប្រឡងត្រូវបដិសេធ ។

៥. ការសិក្សាមានរយៈពេល ២ឆ្នាំ ( មាន ៤ឆមាស ) ដែលមានតំលៃសរុប **២,០០០,០០០ រៀល** ( **ពីរលានរៀលគត់** ) ស្មើនឹង ៥០០$ ( ប្រាំរយដុល្លារអាមេរិក ) ។

៦. និស្សិតក្រៅប្រព័ន្ធធនាគារជាតិ ដែលបានប្រឡងជាប់ជាស្ថាពរ មានកាតព្វកិច្ចបង់តំលៃសិក្សាតាមការកំណត់របស់មណ្ឌលសិក្សាបច្ចេកទេសធនាគារ មួយឆមាសតំលៃ **៥០០,០០០ រៀល** ( **ប្រាំរយពាន់រៀលគត់** ) ស្មើនឹង ១២៥$ ( មួយរយម្ភៃប្រាំដុល្លារអាមេរិក ) ។

**នាយក**

**ចម្លងជូន**

- ឯកឧត្តមអគ្គលេខាធិការធនាគារជាតិនៃកម្ពុជា
  " ដើម្បីជូនជ្រាប "
- នាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា
  " ដើម្បីជូនជ្រាប និងជួយផ្សព្វផ្សាយ "
- ខុទ្ទកាល័យធនាគារជាតិនៃកម្ពុជា
- នាយកដ្ឋានបុគ្គលិកធនាគារជាតិនៃកម្ពុជា
  " ដើម្បីជួយសម្រួល និងជួយផ្សព្វផ្សាយ "
- ឯកសារ-កាលប្បវត្តិ

**ខាំ_និមិត្ត**